الإسلام دين رسل الله)للجمعية(

ឥស្លាមគឺជាសាសនានៃបណ្តាអ្នក

នាំសាររបស់អល់ឡោះ

ឥស្លាមគឺជាសាសនានៃបណ្តាអ្នកនាំសាររបស់អល់ឡោះ

ឥស្លាមគឺជាការចុះចូលចំពោះអល់ឡោះជាម្ចាស់ដែលជាអ្នកបង្កើត និងជាអ្នកគ្រប់គ្រងចក្រវាឡ ហើយធ្វើការគោរពប្រតិបត្តិចំពោះទ្រង់ដោយសេចក្តីស្រឡាញ់ និងការគោរព។ មូលដ្ឋានគ្រឹះនៃសាសនាឥស្លាមគឺការមានជំនឿលើអល់ឡោះថាទ្រង់គឺជាអ្នកបង្កើត
ហើយអ្វីផ្សេងទៀតទាំងអស់គឺត្រូវបានបង្កើត។
ហើយទ្រង់តែមួយគត់ដែលសក្តិសមនឹងទទួលបានការគោរពសក្ការៈដ៏ត្រឹមត្រូវ ដោយគ្មានដៃគូ និងគ្មានអ្នកណាក្រៅពីទ្រង់ដែលប្រៀបបាននឹងទ្រង់ ឬស្មើនឹងទ្រង់ឡើយ។
ទ្រង់មានព្រះនាមដ៏ប្រសើរបំផុត
និងគុណសម្បត្តិខ្ពស់បំផុត
ហើយទ្រង់មានលក្ខណៈល្អឥតខ្ចោះ
ទ្រង់មិនបានប្រសូតអ្នកណា
ក៏មិនត្រូវបានគេប្រសូតទ្រង់ដែរ
ហើយគ្មានអ្នកណាអាចប្រៀបផៀប
ឬតំណាងនឹងទ្រង់បានឡើយ ។ ទ្រង់មិននៅឬរួមបញ្ចូលក្នុងអ្វីទាំងអស់នៃការបង្កើតរបស់ទ្រង់ឡើយ។

សាសនាឥស្លាម ជាសាសនារបស់ព្រះដ៏មហាថ្កុំថ្កើងដែលមិនទទួលយកពីមនុស្សនូវសាសនាផ្សេងឡើយ។

គឺជាសាសនាដែលព្យាការីទាំងអស់នាំមក
សូមសុខសន្តិភាពកើតមានដល់ពួកគាត់។
    អំពីគោលគ្រឹះមួយនៃសាសនាឥស្លាម
គឺការមានជំនឿលើអ្នកនាំសារទាំងអស់របស់អល់
ឡោះ
ដោយទ្រង់បានបញ្ជូនពួកគេមកដើម្បីនាំយកបញ្ជារ
បស់ទ្រង់ទៅកាន់ខ្ទុំបម្រើរបស់ទ្រង់
ហើយបាននាំមកនូវគម្ពីរសម្រាប់ពួកគេ។
ដោយអ្នកនាំសារចុងក្រោយបង្អស់គឺ
អ្នកនាំសារមូហាំម៉ាត់
(សូមសន្តិភាពកើតមានលើគាត់)។
ព្រះជាម្ចាស់បានបញ្ជូនគាត់ជាមួយនឹងបញ្ញត្តិច្បាប់
ស្ថាវរអាត់ចុងក្រោយ
ដោយលុបចោលបញ្ញត្តិច្បាប់របស់អ្នកនាំសារទាំងឡា
យដែលមកមុនគាត់។
ទ្រង់បានប្រទាន់នូវសញ្ញាកស្តតាងដ៏អស្ចារ្យជាច្រើនដ
ល់គាត់
ហើយសញ្ញាកស្តតាងដ៏អស្ចារ្យបំផុតនោះគឺគម្ពីរគួរអា
នដ៏បរិសុទ្ធ
ដែលបន្ទូលរបស់អល់ឡោះជាម្ចាស់នៃភពទាំងអស់។
គម្ពីរដ៏អស្ចារ្យបំផុតដែលមនុស្សជាតិបានស្គាល់អំពីអ
ច្ឆរិយភាពរបស់វាទាំងខ្លឹមសារ
ពាក្យពេចន៍និងរចនាសម្ព័ន្ធផ្សេងៗ
ដែលផ្តុកទៅដោយការណែនាំអំពីសេចក្តីពិតដែលនាំ
ទៅរកសុភមង្គលក្នុងលោកិយនេះ និងថ្ងៃបរលោក។

ហើយវាត្រូវបានរក្សាជាភាសាអារ៉ាប់(ភាសាដើមដែល
គម្ពីរបានបញ្ចេះមក)រហូតមកដល់សព្វថ្ងៃនេះ
ដោយគ្មានការផ្លាស់ប្តូរ ឬកែប្រែ
ទោះបីមួយតួអក្សរនោះឡើយ។
ហើយក្នុងចំណោមគោលគ្រឹះនៃសាសនាឥស្លាម
គឺការមានជំនឿលើបណ្តាម៉ាឡាអ៊ីកាត់(ទេវតា)
និងមានជំនឿចំពោះថ្ងៃបរលោក
ដោយនៅក្នុងថ្ងៃនោះ
ទ្រង់នឹងឱ្យមនុស្សចេញពីផ្នូររបស់ពួកគេមករិញ
ដើម្បីកាត់ក្តីចំពោះទង្វើរបស់ពួកគេ។
អ្នកណាដែលធ្វើអំពើល្អ ហើយជាអ្នកមានជំនឿ
នោះនឹងទទួលបានសេចក្តីសុខជារៀងរហូតនៅក្នុង
ឋានសួគ៌ ហើយអ្នកណាដែលគ្មានជំនឿ
និងធ្វើអំពើអាក្រក់
នោះនឹងមានទទួលទោសយ៉ាងធ្ងន់ធ្ងរបំផុតនៅក្នុង
នរក។
ហើយអំពីគោលគ្រឹះមួយនៃសាសនាឥស្លាមផងដែរ
គឺការមានជំនឿលើអ្វី(វាសនា)ដែលអល់ឡោះបានកំ
ណត់ អំពីប្រការល្អ ឬអាក្រក់។
ហើយអ្នកម៉ូស្លីមគ្រប់រូបជឿថា
យេស៊ូ(អ៊ីសា)គឺជាខ្ញុំបម្រើ
និងជាអ្នកនាំសាររបស់អល់ឡោះ
ហើយគាត់ក៏មិនមែនជាកូនប្រុសរបស់អល់ឡោះដែរ។
ព្រោះអល់ឡោះ ទ្រង់មិនមានប្រពន្ធ ឬកូនប្រុសឡើយ។
ហើយទ្រង់បានប្រាប់យើងនៅក្នុងគម្ពីរគួរអានថា៖

យេស៊ូគឺជាព្យាការីដែលទ្រង់បានប្រទានអច្ឆរិយភាពជាច្រើនដល់គាត់
ហើយអល់ឡោះបានបញ្ជូនគាត់មកឱ្យអំពាវនាវក្រុមរបស់គាត់ឱ្យពួកគេគោរពសក្ការៈចំពោះទ្រង់តែមួយគត់ ដោយគ្មានដៃគូសម្រាប់ទ្រង់ឡើយ។
ហើយទ្រង់បានប្រាប់ថា
យេស៊ូមិនបានសុំអំពាវនាវឱ្យមនុស្សឱ្យគោរពសក្ការៈគាត់ឡើយ
ប៉ុន្តែខ្ពើរពសក្ការៈអល់ឡោះដែលជាអ្នកបង្កើតតែមួយគត់។

សាសនាឥស្លាមជាសាសនាដែលសមស្របនឹងធម្មជាតិពីកំណើតរបស់មនុស្ស និងសតិសម្បជញ្ញៈដ៏ល្អស្របនឹងដួងវិញ្ញាណ។
អល់ឡោះបានដាក់វាជាបញ្ញត្តិច្បាប់សម្រាប់ភាវៈទាំងឡាយដែលទ្រង់បានបង្កើត។ហើយវាគឺជាសាសនានៃសេចក្តីល្អ និងសុភមង្គលសម្រាប់មនុស្សទាំងអស់គ្មានរើសអើងជាតិសាសន៍មួ ឬពណ៌សម្បុរឡើយ។
មនុស្សទាំងអស់
គឺមានភាពស្មើគ្នានៅក្នុងសាសនានេះ
គ្មានអ្នកណាល្អប្រសើរជាងអ្នកណាឡើយ
លើកលែងតែកម្រិតនៃទង្វើល្អប៉ុណ្ណោះដែលធ្វើឲ្យពួកគេមានភាពល្អប្រសើរជាងគ្នា។

ចាំបាច់លើមនុស្សគ្រប់រូបដែលមានប្រាជ្ញាស្មារតីត្រូវជឿលើអល់ឡោះថាជាម្ចាស់ ឥស្លាមជាសាសនា ហើយមូហាំម៉ាត់ជាអ្នកនាំសាររបស់គេ។

នេះគឺជាអ្វីដែលមនុស្សម្នាក់ៗត្រូវទទួលយកដោយគ្មានការជ្រើសរើស។
ព្រោះអល់ឡោះនឹងសួរគេនៅថ្ងៃបរលោកអំពីអ្វីដែលអ្នកនាំសារគេបានឆ្លើយ។
ប្រសិនបើគេជាអ្នកមានជំនឿ
នោះគេនឹងទទួលជោគជ័យ និងភាពសុខសាន្ត
ហើយប្រសិនបើគេជាអ្នកគ្មានជំនឿ
នោះគេនឹងត្រូវខាតបង់យ៉ាងជាក់ច្បាស់ជាមិនខានឡើយ។

អ្នកដែលចង់ចូលសាសនាឥស្លាមត្រូវពោលថា៖ “ខ្ញុំធ្វើជាសាក្សីថា គ្មានព្រះណាដែលត្រូវគោរពសក្ការៈដ៏ត្រឹមត្រូវក្រៅពីអល់ឡោះឡើយ ហើយខ្ញុំធ្វើជាសាក្សីថា មូហាំម៉ាត់ គឺជាអ្នកនាំសាររបស់ទ្រង់” ដោយត្រូវដឹងពីអត្ថន័យរបស់វា ហើយជឿលើអត្ថន័យរបស់វា។ ដោយការធ្វើបែបនេះ គឺគេនឹងក្លាយជាអ្នកមូស្លីម។ បន្ទាប់មក គេត្រូវរៀនអំពីច្បាប់ផ្សេងទៀតនៃសាសនាឥស្លាមបន្តិចម្តងៗ ដើម្បីបានធ្វើអ្វីដែលទ្រង់បានបង្គាប់ឲ្យប្រើឱ្យបានត្រឹមត្រូវ។

សម្រាប់ព័ត៌មានបន្ថែម៖ https://byenah.com/ar/discover-islam

Index

ឥស្លាមគឺជាសាសនានៃបណ្តាអ្នកនាំសាររបស់អល់ឡោះ.....2

km364v2.0 - 04/09/2026